**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ ៤២០២៧ សជណ ៣

រាជធានីភ្នំពេញ ថ្ងៃទី១៨...ខែវិច្ឆិកា ឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ÷ ស្តីពីការពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់។

**យោង** ÷ - ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមុខងារការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- អនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាល
- ប្រកាសលេខ១៨៨៤ ប.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- សាលដីកាលេខ៣៤០ (ធ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាបថា តុលាការកំពូលបានសម្រេចរំលាយគណបក្សសង្គ្រោះជាតិតាមរយៈសាលដីកាលេខ៣៤០ (ធ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។ ផ្អែកតាមសាលដីកានេះ និងផ្អែកតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៃគណបក្សសង្គ្រោះជាតិ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយចាប់ពីពេលនេះតទៅ។ ហេតុនេះ ដើម្បីធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងអំឡុងពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់ **ឯកឧត្តម លោកជំទាវ** ដូចខាងក្រោម៖

–ត្រូវណែនាំដល់រដ្ឋបាលឃុំ សង្កាត់ឱ្យបន្តអនុវត្តតួនាទី ភារកិច្ច ដើម្បីធានាប្រក្រតីភាព និងនិរន្តរភាពក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការអភិវឌ្ឍមូលដ្ឋាន ការផ្តល់សេវា និងការដោះស្រាយសំណើសំណូមពរនានាជូនប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាពស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

-ពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្តនីមួយៗ ឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

-ត្រូវណែនាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យធ្វើការតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រដល់ឃុំ សង្កាត់ក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវានានាជូនប្រជាពលរដ្ឋ។

-ត្រូវពង្រឹងការបំពេញការងាររបស់ស្មៀនឃុំ សង្កាត់ ដោយតម្រូវឱ្យមានវត្តមានជាប្រចាំនៅសាលាឃុំ សង្កាត់នៅរៀងរាល់ថ្ងៃ និងត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវតួនាទី ភារកិច្ចដែលបានកំណត់ក្នុងច្បាប់ លិខិតបទដ្ឋាននានា ដោយយកចិត្តទុកដាក់ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់ ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវានានាជូនប្រជាពលរដ្ឋ។

-ត្រូវតាមដាន ត្រួតពិនិត្យការអនុវត្តតួនាទី ភារកិច្ចគ្រប់ឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន។ ក្នុងករណីឃុំ សង្កាត់ណាដែលអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនមិនបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានជាធរមាន អភិបាលរាជធានី ខេត្តត្រូវធ្វើការសម្របសម្រួល គាំទ្រ និងអាចធ្វើអន្តរាគមន៍ ដើម្បីឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

-ត្រូវរាយការណ៍ប្រចាំថ្ងៃ មកក្រសួងមហាផ្ទៃអំពីស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្នុងរាជធានី ខេត្តនីមួយៗ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវអភិបាល ចាត់ចែងអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព។

សូម ឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ